# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួល មាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/

០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្ដីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម (**ស.ភ.ក.ក.**) ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពការងារ អប់រំបណ្តុះបណ្តាល ការរៀន ការបង្រៀន ការស្រាវជ្រាវ កម្មសិក្សា និងនវានុវត្តន៍របស់សាកលវិទ្យាល័យ។

## ជំពូកទី២
## ភារកិច្ចនិងរចនាសម្ព័ន្ធរបស់ ស.ភ.ក.ក.

**មាត្រា២ .-**

**ស.ភ.ក.ក.** មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមចំណែកអនុវត្តសម្រេចគោលបំណងគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បណ្តុះបណ្តាលធនធានមនុស្សដោយផ្តោតលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្ម ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- សិក្សាស្រាវជ្រាវដោយផ្តោតលើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកសិកម្ម
- គាំពារការងារសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ ស្រាវជ្រាវ អង្គការនានា និងវិស័យឯកជន ដើម្បីជំរុញការងារអប់រំស្រាវជ្រាវ និងអភិវឌ្ឍន៍
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣ .-**

**ស.ទ.ត.ក.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម
- មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ
- មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ
- មហាវិទ្យាល័យព្រៃឈើ
- មហាវិទ្យាល័យជលផលនិងវារីវប្បកម្ម
- មហាវិទ្យាល័យវិស្វកម្មប្រព័ន្ធជីវកសិកម្ម
- មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- មហាវិទ្យាល័យកសិឧស្សាហកម្ម
- មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី
- មហាវិទ្យាល័យអប់រំនិងសារគមនាគមន៍កសិកម្ម
- សាលាក្រោយបរិញ្ញាបត្រ (ថ្នាក់ស្មើមហាវិទ្យាល័យ)
- សាលាបណ្តុះបណ្តាលទេពកោសល្យកសិកម្ម (ថ្នាក់ស្មើមហាវិទ្យាល័យ)
- មជ្ឈមណ្ឌលសិក្សានិងសេវានិស្សិត (ថ្នាក់ស្មើមហាវិទ្យាល័យ)
- មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ (ថ្នាក់ស្មើមហាវិទ្យាល័យ)។

មហាវិទ្យាល័យនីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងព្រឹទ្ធបុរសរង មួយចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលានីមួយៗ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាននាយករងមួយ ចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌលនីមួយៗ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាននាយករង មួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ស.ទ.ត.ក.** អាចស្នើសុំបង្កើតមហាវិទ្យាល័យ សាលា មជ្ឈមណ្ឌល និងអង្គភាពចំណុះផ្សេងទៀតតាមការ ចាំបាច់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **ស.ទ.ត.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពចំណុះផ្សេងទៀត នៃ **ស.ទ.ត.ក.** ត្រូវ កំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

**ស.ទ.ត.ក.** មានសិទ្ធិប្រើត្រានិងរូបសញ្ញាដាច់ដោយឡែក ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួនដែល កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦ .-**

**ស.ឧ.គ.ក.** អាចបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ ក្រុមប្រឹក្សា និងគណៈកម្មការនានាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ជំពូកទី៣**
**ភារកិច្ចរបស់មហាវិទ្យាល័យនិងថ្នាក់ប្រហាក់ប្រហែល**

**មាត្រា៧ .-**

មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្មមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្មស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ឧ.គ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាពសមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គមនិងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ឧ.គ.ក.** ប្រគល់ឱ្យ។

**មាត្រា៨ .-**

មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ឧ.គ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង

- អប់រំបណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្ដល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ភ.ឥ.ភ.** ប្រគល់ឱ្យ។

**មាត្រា៩ .-**

មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វស្របតាម ផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ភ.ឥ.ភ.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្របសុវេជ្ជបណ្ឌិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្ដល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ភ.ឥ.ភ.** ប្រគល់ឱ្យ។

**មាត្រា១០ .-**

មហាវិទ្យាល័យព្រៃឈើមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យព្រៃឈើស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ភ.ឆ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យព្រៃឈើ ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និង តាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ភ.ឆ.ក.** ប្រគល់ឱ្យ។

**មាត្រា១១ .-**

មហាវិទ្យាល័យផលផលនិងវារីវប្បកម្ម មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យផលផលនិងវារីវប្បកម្មស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ភ.ឆ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យផលផលនិងវារីវប្បកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព
- សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលសាកលវិទ្យាធិការប្រគល់ឱ្យ។

**មាត្រា១២ .-**

មហាវិទ្យាល័យវិស្វកម្មប្រព័ន្ធជីវកសិកម្ម មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យវិស្វកម្មប្រព័ន្ធជីវកសិកម្មស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ភ.ឥ.ភ.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យវិស្វកម្មប្រព័ន្ធជីវកសិកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាពសមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ភ.ឥ.ភ.** ប្រគល់ឱ្យ។

**មាត្រា១៣ .-**

មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ភ.ឥ.ភ.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សា

រៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង

- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាពសមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងផ្ញើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ខ.ឆ.ភ.** ប្រគល់ឱ្យ។

**មាត្រា១៤ .-**

មហាវិទ្យាល័យកសិឧស្សាហកម្ម មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗរបស់មហាវិទ្យាល័យកសិឧស្សាហកម្មស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ខ.ឆ.ភ.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យកសិឧស្សាហកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាពសមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គមនិងក្រមសីលធម៌វិជ្ជាជីវៈ

- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ម.ភ.ក.** ប្រគល់ឱ្យ។

**មាត្រា១៥ .-**

មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗរបស់មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ម.ភ.ក.**
- កសាងនិងអភិវឌ្ឍន៍កម្មវិធីសិក្សាមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តយុទ្ធសាស្ត្រនិងផែនការមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ម.ភ.ក.** ប្រគល់ឱ្យ។

**មាត្រា១៦ .-**

មហាវិទ្យាល័យអប់រំនិងសារគមនាគមន៍កសិកម្ម មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់មហាវិទ្យាល័យអប់រំ និងសារគមនាគមន៍កសិកម្ម ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ម.ភ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យអប់រំនិងសារគមនាគមន៍កសិកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់មហាវិទ្យាល័យ
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងសារណាបទឬនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា

- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រមហាវិទ្យាល័យ
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មហាវិទ្យាល័យ
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិមហាវិទ្យាល័យ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គមនិងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ឲ.ឆ.អ.** ប្រគល់ឱ្យ។

**មាត្រា១៧ .-**

សាលាក្រោយបរិញ្ញាបត្រ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗ របស់សាលាក្រោយបរិញ្ញាបត្រ ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ឲ.ឆ.អ.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀននិងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សារៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទរបស់សាលាក្រោយបរិញ្ញាបត្រ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការនិងកម្មវិធីសិក្សារបស់សាលា
- ដឹកនាំនិស្សិតសិក្សាស្រាវជ្រាវនិងចងក្រងនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា
- គ្រប់គ្រងព័ត៌មានស្ថិតិនិស្សិត កម្មវិធីសិក្សា ការអប់រំបណ្តុះបណ្តាល និងត្រួតពិនិត្យតាមដានវាយតម្លៃការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត
- សិក្សាស្រាវជ្រាវ នវានុវត្តន៍ និងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្កើតជាកញ្ចប់បច្ចេកវិទ្យា
- រៀបចំវេទិកាវិទ្យាសាស្ត្រសម្រាប់បុគ្គលិកសិក្សាអប់រំ និស្សិត អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍសាលាក្រោយបរិញ្ញាបត្រ
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រសាលា
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់សាលា
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិសាលាក្រោយបរិញ្ញាបត្រ
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គមនិងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ឲ.ឆ.អ.** ប្រគល់ឱ្យ។

**មាត្រា១៨ .-**

សាលាបណ្តុះបណ្តាលទេពកោសល្យកសិកម្ម មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ ថវិកា និងគម្រោងវិនិយោគផ្សេងៗរបស់សាលាបណ្តុះបណ្តាលទេពកោសល្យកសិកម្ម ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ទ.ភ.ក.**
- កសាងនិងអភិវឌ្ឍកម្មវិធីសិក្សារបស់សាលាបណ្តុះបណ្តាលទេពកោសល្យកសិកម្ម ព្រមទាំងអភិវឌ្ឍវិធីសាស្ត្របង្រៀន ចងក្រងឯកសារបង្រៀន និងបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈសម្រាប់ការសិក្សា រៀនសូត្រ ការពិសោធ ការអនុវត្តជាក់ស្តែងគ្រប់ប្រភេទ ស្របតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យាឌីជីថល ឧស្សាហកម្មជំនាន់ទី៤ និងតាមតម្រូវការទីផ្សារជាក់ស្តែង
- អប់រំបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររង ប្រកបដោយគុណភាព សមត្ថភាពខ្ពស់ ស្របតាមផែនការ និងកម្មវិធីសិក្សា
- បើកវគ្គសិក្សាខ្លីៗលើជំនាញឯកទេសវិជ្ជាជីវៈកសិកម្ម ព័ត៌មានវិទ្យា ភាសាបរទេស ធុរកិច្ច សហគ្រិនភាព និងជំនាញពាក់ព័ន្ធផ្សេងៗ ដល់សិស្ស និស្សិត និងអតិថិជនទូទៅតាមតម្រូវការ
- ផ្តល់សេវាកម្មបច្ចេកទេសពាក់ព័ន្ធជូនដល់អតិថិជន
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍសាលា
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្រសាលា
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់សាលា
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិសាលា
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ទ.ភ.ក.** ប្រគល់ឱ្យ។

**មាត្រា១៩ .-**

មជ្ឈមណ្ឌលសិក្សានិងសេវានិស្សិត មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការនិងថវិការបស់មជ្ឈមណ្ឌលសិក្សានិងសេវានិស្សិត ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ទ.ភ.ក.**
- គ្រប់គ្រងនិងដឹកនាំតម្រង់ទិសនៃការបង្កើតនិងការអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ឯកសារបង្រៀន របស់គ្រប់មហាវិទ្យាល័យនិងសាលា
- រៀបចំយន្តការ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ណែនាំគ្រប់ប្រភេទសម្រាប់បម្រើដល់ការបង្រៀន និងការរៀនរបស់និស្សិត
- គ្រប់គ្រង អភិវឌ្ឍ និងបម្រើសេវាកម្មបណ្ណាល័យ
- បម្រើសេវាកម្មនិងប្រឹក្សាយោបល់ដល់និស្សិតពាក់ព័ន្ធនឹងការសិក្សារៀនសូត្រនិងការរកការងារធ្វើ
- គ្រប់គ្រងទិន្នន័យស្ថិតិនិស្សិត ព័ត៌មានអំពីការសិក្សារៀនសូត្ររបស់និស្សិតនិងសញ្ញាបត្រនិស្សិត
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ទាំងវិស័យឯកជននិងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សានិងសេវានិស្សិត
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌល
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សរបស់មជ្ឈមណ្ឌល
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរបស់មជ្ឈមណ្ឌល
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ

- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ទ.ត.ក.** ប្រគល់ឱ្យ។

**មាត្រា២០ .-**

មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការនិងថវិការបស់មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ស.ទ.ត.ក.**
- រៀបចំយន្តការ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ណែនាំគ្រប់ប្រភេទដើម្បីជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងការផ្ទេរបច្ចេកវិទ្យា
- ទំនាក់ទំនងនិងកៀរគរដៃគូអភិវឌ្ឍន៍ វិស័យសាធារណៈនិងឯកជនជាតិនិងអន្តរជាតិ ដើម្បីស្វែងរកធនធានហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់សកម្មភាពស្រាវជ្រាវ នវានុវត្តន៍ និងផ្ទេរបច្ចេកវិទ្យា
- គ្រប់គ្រង សម្របសម្រួល និងតម្រង់ទិសការស្រាវជ្រាវ នវានុវត្តន៍ និងផ្ទេរបច្ចេកវិទ្យាជាមួយគ្រប់អង្គភាពចំណុះ **ស.ទ.ត.ក.**
- តាមដាននិងវាយតម្លៃការអនុវត្តគម្រោងស្រាវជ្រាវ ចងក្រងរបាយការណ៍គម្រោងស្រាវជ្រាវ និងចាត់ចែងការបោះពុម្ពលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ
- រៀបចំចាត់ចែងធ្វើសន្និសីទវិទ្យាសាស្ត្រទាំងថ្នាក់ជាតិនិងអន្តរជាតិ
- អភិវឌ្ឍសមត្ថភាពធនធានមនុស្សលើការស្រាវជ្រាវនិងបង្កើតយន្តការនានា ដើម្បីប្រសិទ្ធភាពក្នុងការរៀបចំគម្រោងស្រាវជ្រាវ ការស្រាវជ្រាវ ការសរសេរអត្ថបទវិទ្យាសាស្ត្រ ការបោះពុម្ពផ្សាយ និងការប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវនិងនវានុវត្តន៍
- អនុវត្តយន្តការអង្គភាពនិងយន្តការប្រតិបត្តិសម្រាប់អនុវត្តផែនការនិងយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌល
- ចូលរួមជ្រើសរើស ថែរក្សា គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់មជ្ឈមណ្ឌល
- គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរបស់មជ្ឈមណ្ឌល
- អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌វិជ្ជាជីវៈ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលសាកលវិទ្យាធិការ **ស.ទ.ត.ក.** ប្រគល់ឱ្យ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា២១ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនានាចំណុះ **ស.ទ.ត.ក.** ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០២៣
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**អង្គការលេខរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

